**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
**នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ**
លេខ......១៤៣៣......កសស.គណ.ហវ

ថ្ងៃសុក្រ ១០កើត ខែ មិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
ខេត្តព្រះសីហនុ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២៣

# សេចក្តីប្រកាសព័ត៌មាន

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) មានសេចក្តីសោមនស្សរីករាយ ជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា ៖ **កសស** បានទទួលនូវរថលើកដាក់ចល័តនៅគែមផែ (Mobile Harbor Cranes) ចំនួន ២គ្រឿង ដែលមានសមត្ថភាពអាចលើកដាក់ទំនិញទូទៅជាអតិបរមា ១០០ តោន និងលើកកុងតែន័រជាមធ្យម ១៥ កុងតែន័រ/ម៉ោង ហើយមានតម្លៃ សរុបប្រហែល ចំនួន ១៣,៩ លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងពីរដ្ឋាភិបាល នៃប្រទេសជប៉ុន ហើយបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ នេះផងដែរ ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសម្ពោធបើកការដ្ឋានសាងសង់ចំណតផែកុងតែន័រទឹកជ្រៅថ្មីដំហានទី១ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការគ្រឿងចក្រលើកដាក់ចល័តនៅគែមផែ ចំនួន ២ គ្រឿង ដែលបានប្រារព្ធនៅតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

PORT AUTONOME DE SIHANOUKVILLE

តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh